មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ព្រឹត្តិបត្រព័ត៌មានស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌
## សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ និងការពន្យល់ប្រាប់សិទ្ធិដល់ជនជាប់ចោទជាស្ត្រី

www.cchrcambodia.org

លេខ១២៖ ខែ មីនា ឆ្នាំ២០២១

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) បានធ្វើការសង្កេតការណ៍សវនាការចាប់ពីឆ្នាំ២០០៩ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌនៅតុលាការកម្ពុជា និងវាយតម្លៃអំពីការអនុវត្តការជំនុំជម្រះដោយយុត្តិធម៌ តាមបទដ្ឋានជាតិ និងអន្តរជាតិ។ ចាប់តាំងពីខែមីនា ឆ្នាំ ២០១៣ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក បានសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ។ ព្រឹត្តិបត្រព័ត៌មាននេះគឺជាផ្នែកនៃការចេញផ្សាយជាស៊េរីដែលវិភាគលើរបកគំហើញពីការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក។ ព្រឹត្តិបត្រព័ត៌មាននេះផ្ដោតលើកាតព្វកិច្ចរបស់ចៅក្រមក្នុងការថ្លែងប្រាប់ជនជាប់ចោទជាស្ត្រី ពីការចោទប្រកាន់ដែលពាក់ព័ន្ធទាំងអស់ប្រឆាំងនឹងពួកគេ និងកាតព្វកិច្ចរបស់ចៅក្រមក្នុងការពន្យល់ជនជាប់ចោទជាស្ត្រីអំពីសិទ្ធិមានមេធាវី ឬការការពារដោយខ្លួនឯង ព្រមទាំងសិទ្ធិនៅស្ងៀម ដើម្បីចៀសវាងការដាក់បន្ទុកលើខ្លួនឯង។ រាល់ទិន្នន័យដែលទទួលបាន គឺមានផ្សព្វផ្សាយជាសាធារណៈក្នុងប្រព័ន្ធផ្ទុកទិន្នន័យការសង្កេតការណ៍សវនាការរបស់យើង។

> **មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា៖**
>
> “ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់មកលើខ្លួន។”
>
> **មាត្រា ១៤(៣) (ក) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**
>
> “ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិត្រូវទទួលបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ។”

### *ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ និងភាពស្មើគ្នាចំពោះមុខច្បាប់*

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) ចែងថា ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ដោយមិនប្រកាន់យេនឌ័រ រីឯមាត្រា ៤៥ លុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងចែងថា បុរស និងស្ត្រីមានសិទ្ធិ“*ស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់*”។

ទាំងបទដ្ឋាននៃច្បាប់ជាតិ និងអន្តរជាតិចែងថា ជនជាប់ចោទគ្រប់រូបដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ រួមទាំងជនជាប់ចោទជាស្ត្រី ត្រូវតែទទួលបានការពន្យល់ប្រាប់ពីប្រភេទនៃបទល្មើសដែលពួកគេត្រូវបានចោទប្រកាន់នៅគ្រាដំបូងបង្អស់។ ចៅក្រមមានកាតព្វកិច្ចក្នុងការពន្យល់ឱ្យបានគ្រប់គ្រាន់ និងច្បាស់ថា ជនជាប់ចោទយល់ពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន។ ប្រសិនបើគ្មានព័ត៌មានសំខាន់ទាំងនេះទេ នោះមិនអាចរៀបចំការពារក្ដី ឬដើម្បីផ្ដល់ព័ត៌មានគ្រប់គ្រាន់ដល់មេធាវី ក្នុងករណីដែលជនជាប់ចោទមានមេធាវីតំណាង។ បន្ថែមលើនេះ ចៅក្រមក៏ត្រូវតែប្រាប់ជនជាប់ចោទជាស្ត្រីពីសិទ្ធិស្វែងរកមេធាវី ឬការការពារខ្លួនឯងផងដែរ។ ចៅក្រមត្រូវតែធានាបន្ថែមទៀតថា ជនជាប់ចោទដឹងពីសិទ្ធិនៅស្ងៀម និងមិនសារភាពពីពិរុទ្ធភាព។ ការប្រាប់ឲ្យដឹងពីសិទ្ធិបែបនេះ ចៅក្រមត្រូវតែធ្វើនៅអំឡុងពេលសវនាការមុនគេបង្អស់។

សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការការពារខ្លួនមានចែងនៅមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ រីឯមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា “*អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាជាពលរដ្ឋ*”។ ចៅក្រមត្រូវតែបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឹងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ តាមមាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (“ក្រមនីតិវិធីព្រហ្មទណ្ឌ”) ចែងថា ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន។ ដូចនៅមាត្រា ៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងពីការពន្លាតនូវវិធានដែលអនុវត្តចំពោះសាលាដំបូងដល់សាលាឧទ្ធរណ៍ផងដែរ។ មាត្រាទាំងនេះក៏អនុវត្តចំពោះអនីតិជនផងដែរ៖ មាត្រា ៥១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជនចែងថា “*ពេលចាប់ផ្ដើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសា ដែលអនីតិជនអាចយល់បានអំពីសិទ្ធិដូចខាងក្រោម៖ សិទ្ធិដែលទាក់ទងនឹងដំណាក់កាលជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ*”។

បន្ថែមលើនេះ មាត្រា ១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ក.អ.ស.ព.ន”) ដែលកម្ពុជាជារដ្ឋភាគី និងត្រូវបានបញ្ចូលទៅក្នុងច្បាប់ជាតិតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា “ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងលើខ្លួន បុគ្គលគ្រប់រូបមានសិទ្ធិត្រូវទទួលបាន*ព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។*” កថាខណ្ឌ (៣)(ឃ) នៃមាត្រានេះចែងបន្ថែមថា បុគ្គលគ្រប់រូបត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន។ ជនជាប់ចោទក៏ត្រូវបានប្រាប់ឲ្យដឹងពីសិទ្ធិទទួលបានជំនួយផ្លូវច្បាប់នេះប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ទេនោះ។ ជាចុងក្រោយ កថាខណ្ឌ

CC BY NC SA

(៣)(ធ) នៃមាត្រាដដែលនេះការពារបុគ្គលពីការឆ្លើយដាក់បន្ទុកលើខ្លួនឯង ដែលប្រឆាំងនឹងការប្រើកម្លាំងបង្ខំ ឬការគំរាមដើម្បីទទួលបានការសារភាពអំពីពិរុទ្ធពីជនណាមួយ។

អនុលោមតាមមាត្រា ២ នៃ ក.អ.ស.ព.ន កម្ពុជាត្រូវគោរព និងធានាឱ្យមានការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងនៅក្នុងមាត្រា ១៤ និងចាត់វិធានការចាំបាច់ដើម្បីអនុម័តច្បាប់ ឬវិធានការចាំបាច់ដទៃទៀត ដើម្បីផ្តល់នូវប្រសិទ្ធភាពដល់ការអនុវត្តសិទ្ធិទាំងនោះ។ ការអនុវត្តការពន្យល់ប្រាប់សិទ្ធិនៅដំណាក់កាលជំនុំជម្រះគឺចាំបាច់ដើម្បីធានាថា ជនជាប់ចោទមានឱកាសក្នុងការរៀបចំការពារក្តីយ៉ាងល្អបំផុត តាមដែលអាចធ្វើបានដើម្បីតតាំងនឹងការចោទប្រកាន់ណាមួយមកលើខ្លួន។

## *របកគំហើញនៃការសង្កេតការណ៍របស់ ម.ស.ម.ក*

នៅចន្លោះថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ និង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ម.ស.ម.ក បានសង្កេតការណ៍សវនាការចំនួន ២០០ សំណុំរឿងនៅសាលាឧទ្ធរណ៍ភ្នំពេញ។ ក្នុងចំណោមសំណុំរឿងចំនួន១៧ មានជនជាប់ចោទជាស្ត្រីចំនួន១៨ នាក់។ ម.ស.ម.ក បានសង្កេត ថាតើតុលាការបានប្រាប់ពីបទចោទប្រកាន់ដែលពាក់ព័ន្ធទាំងអស់ និងប្រាប់ជនជាប់ចោទជាស្ត្រីអំពីសិទ្ធិរបស់គេនៅក្នុងនីតិវិធីតុលាការ ព្រមទាំងថាតើតុលាការបានពន្យល់ឲ្យបានពេញលេញដល់ពួកគេអំពីសិទ្ធិដូចជា៖ សិទ្ធិទទួលបានព័ត៌មាន និងយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ សិទ្ធិមានមេធាវី ឬការពារដោយខ្លួនឯង និងសិទ្ធិនៅស្ងៀម។

ម.ស.ម.ក បានរកឃើញថា នៅអំឡុងពេលសង្កេតការណ៍សវនាការ ចៅក្រមបានប្រាប់ពីបទចោទប្រកាន់ដែលពាក់ព័ន្ធទាំងអស់ប្រឆាំងនឹងជនជាប់ចោទជាស្ត្រីនៅក្នុងសំណុំរឿងភាគច្រើន ពោលគឺមានសំណុំរឿងចំនួន ១៦ (៩៤%) ក្នុងសំណុំរឿងដែលបានសង្កេតការណ៍។ ទោះបីជាយ៉ាងនេះក្តី មានសំណុំរឿងចំនួន ០១ (៦%) ដែលជនជាប់ចោទជាស្ត្រីត្រូវបានប្រាប់តែផ្នែកខ្លះនៃបទចោទប្រកាន់តែប៉ុណ្ណោះ។

ចំពោះសិទ្ធិមានមេធាវីសម្រាប់ជនជាប់ចោទជាស្ត្រី ឬការការពារដោយខ្លួនឯង ចៅក្រមគ្រាន់តែបានប្រាប់ជនជាប់ចោទអំពីសិទ្ធិនេះ នៅក្នុងសំណុំរឿងចំនួន ០៣ (១៨%)។ ចៅក្រមមិនបានទាំងប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិនេះ នៅគ្រប់សំណុំរឿងទាំងអស់ទាក់ទងនឹងជនជាប់ចោទជាស្ត្រី ដែល ម.ស.ម.ក បានសង្កេតការណ៍។ នៅក្នុងសំណុំរឿងដែលបានសង្កតការណ៍ មិនមានសំណុំរឿងណាមួយ ដែលចៅក្រមបានប្រាប់ និងពន្យល់ពីសិទ្ធិមានមេធាវី ឬការការពារដោយខ្លួនឯង ដល់ជនជាប់ចោទជាស្ត្រីនោះទេ។ ក្នុងចំណោមសំណុំរឿងចំនួន ១២ (៧០%) ជនជាប់ចោទមានមេធាវីតំណាង ហេតុដូចនេះចៅក្រមមិនចាំបាច់ប្រាប់ពីសិទ្ធិមានមេធាវីឡើយ។ សំណុំរឿងចំនួន ០២ (១២%) ជនជាប់ចោទមិនមានវត្តមាននៅពេលសវនាការ។

ចំពោះសិទ្ធិនៅស្ងៀម ចៅក្រមបានប្រាប់ និងពន្យល់អំពីសិទ្ធិនេះដល់ជនជាប់ចោទ នៅក្នុងសំណុំរឿងចំនួន ០២ (១២%)។ ក្នុងចំណោមសំណុំរឿងចំនួន ០៧ (៤១%) ចៅក្រមបានត្រឹមតែប្រាប់ជនជាប់ចោទជាស្ត្រីអំពីសិទ្ធិនៅស្ងៀមនេះ។ សំណុំរឿងចំនួន ០៦ (៣៥%) ចៅក្រមមិនបានទាំងប្រាប់ និងពន្យល់អំពីសិទ្ធិនេះទេ។ ជាចុងក្រោយ ក្នុងចំណោមសំណុំរឿងចំនួន ០២ (១២%) ជនជាប់ចោទជាស្ត្រីមិនមានវត្តមាននៅពេលសវនាការ។

## *សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ និងការពន្យល់ប្រាប់សិទ្ធិជាតួលេខ*







*មិនពាក់ព័ន្ធ៖ ជនជាប់ចោទអវត្តមាននៅពេលសវនាការ




BY NC SA

នៅក្នុងឆ្នាំ២០២០ ម.ស.ម.ក បានសង្កេតការណ៍សំណុំរឿងទាក់ទងនឹងជនជាប់ចោទជាស្ត្រីមានចំនួនតិច ហើយបើផ្អែកតាមតួលេខខាងលើបង្ហាញថា តុលាការបានគោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់ជនជាប់ចោទជាស្ត្រីបានមួយចំនួន ហើយនៅមានសំណុំរឿងមួយចំនួនទៀត ការអនុវត្តរបស់តុលាការមិនទាន់ឆ្លើយតបពេញលេញនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅឡើយ។ ដូច្នោះ តុលាការគួរតែគោរពសិទ្ធិរបស់ជនជាប់ចោទជាស្ត្រី និងជនជាប់ចោទដទៃទៀតឲ្យបានពេញលេញដែលអនុលោមទៅតាមបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះ។

## អនុសាសន៍៖

ម.ស.ម.ក អំពាវនាវដល់ចៅក្រមនៃតុលាការនៅក្នុងប្រទេសកម្ពុជាគួរ៖

- ប្រាប់ជនជាប់ចោទជាស្ត្រីអំពីការចោទប្រកាន់ប្រឆាំងនឹងពួកគេ និងពន្យល់ពួកគេអំពីការចោទប្រកាន់ទាំងនេះឲ្យបានពេញលេញ។
- ប្រាប់ជនជាប់ចោទជាស្ត្រីអំពីសិទ្ធិរបស់ពួកគេនៅពេលសវនាការ រួមមានសិទ្ធិមានមេធាវី ឬការពារដោយខ្លួនឯង និងសិទ្ធិនៅស្ងៀមនៅពេលសវនាការ និងពន្យល់ឲ្យបានពេញលេញអំពីសិទ្ធិទាំងនេះដល់ពួកគេ។
- លើកកម្ពស់ការអនុវត្តសិទ្ធិរបស់ជនជាប់ចោទជាស្ត្រីឱ្យបានពេញលេញតាមរយៈការជំនុំជម្រះ។
- អនុវត្តឲ្យបានពេញលេញនូវគោលគំនិតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយផ្អែកលើបទដ្ឋានច្បាប់ជាតិ និងអន្តរជាតិ និង
- ប្រតិបត្តិតាមការអនុវត្តល្អនៅក្នុងអង្គជំនុំជម្រះវិសាញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក លេខមុនៗ អាចរកបានតាមប្រព័ន្ធអ៊ីនធឺណិត (លេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ លេខ៦ លេខ៧ លេខ៨ លេខ៩ លេខ១០ និងលេខ១១)។ លោកអ្នកក៏អាចអានរបាយការណ៍ប្រចាំឆ្នាំ២០១៨ របាយការណ៍ប្រចាំឆ្នាំ២០១៩ និងរបាយការណ៍ឆ្នាំ២០២០ របស់យើងស្តីពី"សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍" ដែលបានបង្ហាញពីបេកគំហើញសំខាន់ៗពីការសង្កេតការណ៍របស់ខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ។